**BMI0044**

## សម្ភាសជាមួយឈ្មោះ គៅ ថូន ភេទប្រុស អាយុ៥២ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ ទាហាន

## មុខងារបច្ចុប្បន្នៈ កសិករ

## មានស្រុកកំណើតនៅៈ ភូមិតាំនៃ ឃុំពួក ស្រុកពួក ខេត្តសៀមរាប

## សព្វថ្ងៃរស់នៅភូមិថ្មី ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១៧ ខែតុលា ឆ្នាំ ២០១០

## សម្ភាសន៍ដោយៈ ឡុង ដានី

## ០០:៥៧:៤៦

## ២២ទំព័រ

ដានី ៖ ដំបូងខ្ញុំសុំស្គាល់ឈ្មោះពូ ពូឈ្មោះអីដែរ?

ថូន ៖ ឈ្មោះ គៅ ថូន ។

ដានី ៖ ឈ្មោះកំណើតពូឈ្មោះអញ្ចឹងដែរ?

ថូន ៖ បាទ!ឈ្មោះអញ្ចឹងដែរ ។

ដានី ៖ សព្វថ្ងៃពូអាយុប៉ុន្មានហើយ?

ថូន ៖ ខ្ញុំអាយុ៥២ ។

ដានី ៖ សព្វថ្ងៃពូរស់នៅក្នុងភូមិ ឃុំអីដែរ?

ថូន ៖ រស់នៅភូមិថ្មី ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

ដានី ៖ បាទ!គ្រួសារពូគាត់ឈ្មោះអីដែរ?

ថូន ៖ ឈ្មោះ ពិ ភឿន ។

ដានី ៖ គាត់អាយុប៉ុន្មានហើយ?

ថូន ៖ អាយុ៣៧ ។

ដានី ៖ ពូមានកូនចៅប៉ុន្មាននាក់?

ថូន ៖ មានកូន៤នាក់ ។

ដានី ៖ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

ថូន ៖ ប្រុស៣ ស្រី១ ។

ដានី ៖ បាទ!ធំៗអស់ឬនៅ?

ថូន ៖ ធំអស់នេះមួយ នោះមួយ ។

ដានី ៖ ពូប្រកបរបរធ្វើអីដែរ?

ថូន ៖ ធ្វើស្រែ ធ្វើតែស្រែទេ អត់មានចំការទេ ។

ដានី ៖ អ្ហូ!អត់មានចំការទេ?

ថូន ៖ អត់ទេ!

ដានី ៖ ពូមានដីប៉ុន្មានដែរ?

ថូន ៖ មានតែ ៨រ៉ៃទេ ។

ដានី ៖ ចុះហូបគ្រប់គ្រាន់ដែរឬអត់?

ថូន ៖ ទេ!បើឆ្នាំណាធ្វើកើតហូបគ្រប់គ្រាន់ បើឆ្នាំណាភ្លៀងរាំងទៅហូបខ្វះទៅ ដូចឆ្នាំនេះ ។

ដានី ៖ អត់មានធ្វើចំការអីទេ?

ថូន ៖ អត់មានទេ!

ដានី ៖ ចុះស្រុកកំណើតពូនៅណាដែរ?

ថូន ៖ នៅភូមិតានៃ ឃុំពួក ស្រុកពួក ខេត្តសៀមរាប ។

ដានី ៖ ឪពុកម្ដាយពូគាត់ឈ្មោះអីដែរ?

ថូន ៖ ឪពុកឈ្មោះ ហាប់ ម្ដាយឈ្មោះ ណេប ។

ដានី ៖ សព្វថ្ងៃគាត់នៅ?

ថូន ៖ គាត់ស្លាប់អស់ហើយ ។

ដានី ៖ ស្លាប់តាំងពីអន្កាល់?

ថូន ៖ ស្លាប់តាំងពីឆ្នាំ៨៦ ។

ដានី ៖ ពីឆ្នាំ៨៦ហ្នឹងតែឪពុកឬម្ដាយ?

ថូន ៖ ស្លាប់ទាំងពីនាក់ ។

ដានី ៖ មូលហេតុអីបានគាត់ស្លាប់ហ្នឹង?

ថូន ៖ គាត់ចាស់ហើយ ។

ដានី ៖ គាត់ស្លាប់នៅក្នុងឆ្នាំជាមួយគ្នា?

ថូន ៖ បាទ!

ដានី ៖ ចុះបងប្អូនបង្កើតមានប៉ុន្មាននាក់?

ថូន ៖ មាន៧នាក់ ។

ដានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ជូន ៖ ស្រី៣ ប្រុស៤

ដានី ៖ ចុះពូរៀនសូត្រដល់ណាដែរកាលពីក្មេង?

ជូន ៖ ខ្ញុំរៀនថ្នាក់ទី១០កាលពីសង្គម ។

ដានី ៖ ហើយឈប់រៀនឆ្នាំណា?

ជូន ៖ ខ្ញុំឈប់រៀនឆ្នាំ៧០ ។

ដានី ៖ មូលហេតុអីបានរៀនថ្នាក់ទី១០ហើយឈប់?

ជូន ៖ រដ្ឋប្រហារ ។

ដានី ៖ អ្ហូ!រដ្ឋប្រហារទំលាក់សម្ដេច បាទ!ឈប់ហើយយ៉ាងម៉េចទៀតទៅ?

ជូន ៖ ឈប់ហើយខ្ញុំទៅនៅស្រុកគេ ខ្ញុំទៅនៅក្នុងតំបន់ខ្មែរក្រហម ។

ដានី ៖ អ្ហូ!យើងចូលបដិវត្តន៍?

ជូន ៖ បាទៗ!

ដានី ៖ កាលហ្នឹងយើងស្ម័គ្រចិត្តចូលឬក៏យ៉ាងម៉េច?

ជូន ៖ កាលហ្នឹងខ្ញុំនៅតូច ឪពុកម្ដាយខ្ញុំនៅខាង គេហៅកងរំដោះនោះណា៎ ដល់អញ្ចឹងខ្ញុំក៏ឪពុកម្ដាយយកទៅនៅជាមួយគាត់ ។

ដានី ៖ អ្ហូ!អញ្ចឹង?

ជូន ៖ បាទ!ហើយក៏ឈប់រៀនត្រឹមហ្នឹងទៅ ។

ដានី ៖ ទៅនៅជាមួយទៅនៅណាទៅ?

ជូន ៖ ទៅនៅស្រុកលើ គេហៅអន្លុងវ៉ែង ស្រុកពួកដែលមិនដឹង ខេត្តសៀមរាបដែរ ។

ដានី ៖ កាលហ្នឹងទៅខាងតមបន់រំដោះ?

ជូន ៖ បាទ!

ដានី ៖ កាលហ្នឹងពូអាយុប៉ុន្មាន?

ជូន ៖ កាលនោះខ្ញុំអាយុប្រហែលជា១២-១៣ឆ្នាំ ។

ដានី ៖ ពូធ្វើអីទៅកាលហ្នឹង?

ជូន ៖ អត់ធ្វើអីផង នៅក្នុងបន្ទប់ឪពុកម្ដាយ ។

ដានី ៖ នៅរហូតដល់ពេលណា?

ជូន ៖ នៅរហូតដល់ឆ្នាំ៧៤ គាត់ចូលក្នុងកងរំដោះខ្មែរក្រហម ។

ដានី ៖ កាលហ្នឹងយើងនៅកងរំដោះខ្មែរក្រហមយើងធ្វើអីគេទៅ ធ្វើកងទ័ពឬក៏?

ថូន ៖ ធ្វើកងទ័ព នៅអង្គរ ។

ដានី ៖ កាលហ្នឹងមានកងពលឬនៅកាលហ្នឹង?

ថូន ៖ កាលនោះកងវរៈសេនាធំឯករាជ្យ វរៈសេនាធំឈ្មោះ ឡុន ។

ដានី ៖ នៅអង្គររហូតដល់?

ថូន ៖ រហូតដល់ឆ្នាំ៧០ មុនរំដោះបន្តិចនោះគេបញ្ជូនទៅភ្នំពេញ ដ៏ទៅដល់នៅកំពង់ថ្ម នៅបារាយណ៍កំពង់ថ្មគេវ៉ៃបែកភ្នំពេញ ដល់អញ្ចឹងចូលទៅនៅភ្នំពេញរហូតទៅ ។

ដានី ៖ បាទ!ទៅនៅភ្នំពេញនៅធ្វើអីទៅ?

ថូន ៖ ទៅនៅភ្នំពេញបានដាក្នុះខែ បានគេបញ្ជូនទៅនៅកំពង់សោម នៅធ្វើកម្មករនៅកំពង់សោម នៅកម្មករកំពង់សោមរហូតបាន៧៩ ។

ដានី ៖ បាទ!នៅកន្លែងកម្មករកំពង់សោមធ្វើអីទៅ?

ថូន ៖ កម្មករលើកដាក់លើកប៉ាល់ ។

ដានី ៖ លើកដាក់ទំនិញទៅមកទៅម៉ោ?

ថូន ៖ បាទ!

ដានី ៖ ទំនិញមានអីខ្លះទៅ?

ថូន ៖ មានសព្វមុខ មានតាំងពីលើកកៅស៊ូចូលកប៉ាល់ទៅបរទេស កៅស៊ូ អង្ករ មានល្ងរ ហើយមានអី មានសំភារៈយោធា ដែក សំភារៈក៏សាងប្រទេសផង ។

ដានី ៖ ម៉ោពីណាម៉ោ?

ថូន ៖ ម៉ោពីចិន ម៉ោពី ខាងណាខ្លះទេ អត់សូវដឹងដែរ ។

ដានី ៖ ហើយកាលហ្នឹងកងរបស់ពូនៅអង្គរហ្នឹងទៅកំពង់សោមទាំងអស់ឬក៏យ៉ាងម៉េច?

ថូន ៖ ទៅទាំងអស់ ម៉ាវរៈសោនាធំ ។

ដានី ៖ ដូចឈ្មោះ ឡុន ហ្នឹងគាត់ទៅដែរ?

ថូន ៖ ទៅ បាទ!គាត់ទៅដល់នៅអីគេហៅនៅក្បែរកេងកង ភ្លូកឡាន ក្រឡាប់ឡានក៏ដាច់ជើងត្រឹមហ្នឹង ។

ដានី ៖ អ៊ូ!កន្លែងកងកេង កន្លែងព្រលានយន្តហោះ?

ថូន ៖ បាទ!ដាច់ជើងដ៏ដាច់ជើងទៅ ប៉ុនគាត់នៅកាន់វរៈសេនាធំហ្នឹងដដែល ។

ដានី ៖ បាទ!អញ្ចឹងពូនៅកំសោមរហូតដល់ឆ្នាំ៧៩?

ជូន ៖ បាទ!៧៩រត់ចេញម៉ោៗតាមកោះកុង ។

ដានី ៖ កាលហ្នឹងម៉េចបានអ៊ី! ពេល៧៩យួនចូលហ្នឹងម៉េចបានអត់ម៉ោផ្ទះ?

ជូន ៖ បើនិយាយទៅវាវែងឆ្ងាយណាស់ វារស់នៅក្នុងរបបគេ ដល់អញ្ចឹងការឃោសនា ការអប់រំរបស់គេវាដូចថាវាឆ្អិន ដល់អញ្ចឹងវាអត់មានទឹកឃើញពីរឿងការរត់ទៅផ្ទះទេខ្លាចព្រោះពុថាយួនសម្លាប់នោះ ដល់អញ្ចឹងអត់ហាន ដល់អញ្ចឹងគេនាំទៅចេះតែទៅតាមគេទៅព្រោះខ្លាចគេសម្លាប់នោះ ។

ដានី ៖ អ្ហូ!ឆ្នាំ៧៩ហ្នឹង?

ជូន ៖ បាទ!

ដានី ៖ ពេលយួនចូលហ្នឹង?

ជូន ៖ ទៅទាំងអង្គភាព ។

ដានី ៖ ទាំងអង្គភាពនៅកំពង់សោមហ្នឹងទៅទាំងអស់?

ជូន ៖ អត់ទេ!ទៅមិនអស់ទេ អាចមានគេនៅខ្លះតាមមើល ។

ដានី ៖ ទៅយ៉ាងម៉េចទៅ ពូអាចរៀបរាប់ឆ្នាំ៧៩ពេលយើងរត់ហ្នឹង ដូចថាស្ថានភាពពេលហ្នឹងយ៉ាងម៉េច អាចជួបប្រទះអីនៅតាមផ្លូវពីកន្លែងណាទៅកន្លែងណាអី?

ជូន ៖ ពេលដែលរត់ហ្នឹង បើនិយាយទៅវាវែងឆ្ងាយដែល រត់ចេញពីកំពង់សោមម៉ោ មកដល់តំបន់គេហៅស្រុកថ្មស ។

ដានី ៖ ថ្មស កោះកុងហ្នឹង?

ជូន ៖ បាទ!ថ្មសថ្មបាំងកោះកុងហ្នឹង កាលហ្នឹងវាមានកម្មករផ្សេង ហើយទ័ពនៅតមបន់នោះផ្សេងហើយដឹងអញ្ចឹងរត់ម៉ោហ្នឹងរ៉ៃតាមហ្នឹងរហូត ព្រោះពយកខ្ញុំអត់មានកាំភ្លើងទេកម្មករហ្នឹង ដល់អញ្ចឹងនៅតាមហ្នឹងគេរាយៗរ៉ៃពួកកម្មករ ដល់អញ្ចឹងគេថាពួកកម្មករចេញពីកំពង់សោមសុទ្ធតែក្បត់ទេ ដល់អញ្ចឹងគេរាយរ៉ៃ ដល់អញ្ចឹងចេះរត់គេចបែកខ្ញែកគ្នាខ្លះជាក្រុមជាកងអញ្ចឹងទៅ រត់រហូតម៉ោនៅកន្លែងថ្មបាំងនៅបានប្រហែលជា២ខែដែរ ដល់អញ្ចឹងបានរត់គមកទៀតមកដល់នៅសមុទ្រក្លោងយ៉ៃថៃ ដល់អញ្ចឹងបានអង្គភាពគេនេះគេរើសយកចូលទ័ពវិញក៏ស្ម័គ្រចិត្តចូលវិញ នឹកឃើញថានៅស្រុកថៃវាយ៉ាប់អត់អីហូប ។

ដានី ៖ នៅក្លោងយៃហ្នឹង?

ជូន ៖ បាទ!

ដានី : ខាងណាគេម៉ោរើសទ័ព?

ថូន : ខាងអគ្គភាពនៅស្រុកថៃនេះ កាលនោះអត់នៅនេះទេ កាលនោះនៅខ្មែរ ។

ដានី : នៅត្រាង?

ថូន : បាទៗ! ត្រាង ។

ដានី : កាលហ្នឹងក្មេងយៃយើហើយនឹងខ្មែរនៅជិតគ្នាអត់?

ថូន : អត់ទេ!ឆ្ងាយ ។

ដានី : ចុះម៉េចបានគេទាក់ទងគ្នាបាន?

ថូន : មិនដឹងយ៉ាងម៉េច ដល់ពេលគេថាឥឡូវរើសទៅទ័ព រើសទៅទ័ពក៏ស្មគ្រ័ចិត្តម៉ោ ឡើងឡានម៉ោ ក៏គេបញ្ជូនម៉ោក៏គេបញ្ជូនម៉ោ ជិះឡានយូរដែរ ជិះឡានឡើងចង់១ថ្ងៃដែរ បានមកដល់ខ្មែរ ម៉ោដល់ឃើញទ័ពគេមកទទួលហើយក៏រស់នៅហ្នឹងជាមួយគេរហូត ទៅ ។

ដានី : ពេលហ្នឹងចូលទ័ពនៅខ្មែរហ្នឹងទៅ?

ថូន : បាទ!

ដានី : ចូលទ័ពគេរៀបចំយ៉ាងម៉េចទៀត ជាក្រុមឬកង?

ថូន : ដឹម៉ោគេរៀបចំតាមក្រុមៗ កាលនោះពួកខ្ញុំនោះមានម៉ាវរៈសេនាតូច វរៈសេនាតូចនេះមាន ឈឹម មន្នី គណៈស្រុកនេះគាត់នៅប្រធាន នៅហ្នឹងទៅរហូតដល់ឆ្នាំ៨០ ៗ បានបញ្ជូនអគ្គភាពខ្ញុំមកនៅនេះ ។

ដានី : អូ!កាលហ្នឹងនៅខ្មែរហ្នឹងមានកងពលវរៈសេនាតូចទេ?

ថូន : មានកងពល កងពលនៅក្តាប់នេះបើនិយាយទៅកងពលមាន ចៀម ចៀមគាត់កង ពល បើនិយាយគាត់ជនជាតិ ។

ដានី : គាត់ជនជាតិអីទេ?

ថូន : ជនជាតិ ចារាយ ម៉េចទេខ្ញុំអត់សូវដឹងដែរ ។

ដានី : តា ចៀម ភូមិដូងហ្នឹង?

ថូន : បាទ!

ដានី : គាត់កងពល?

ថូន : បាទ!គាត់កងពល មានចៀម ហើយ ហុង សួរ ហុង ។

ដានី : សួរ ហុង គាត់កងពលដែរ?

ថូន : បាទ! ហើយឈឹម មន្នី ហ្នឹងគាត់កាលនោះវរៈសេនាតូចទេ ដល់ម៉ោនៅនេះគាត់ឡើងវរៈសេនាធំ ដំបូងនៅឆ្នាំ៨០ ។

ដានី : អញ្ចឹងពីខ្មែរម៉ោហ្នឹងឆ្នាំ៨០ យើងផ្លាស់មកនៅនេះ?

ថូន : បាទ! ផ្លាស់ម៉ោនៅនេះ ។

ដានី : ម៉េចបានគេផ្លាស់មកនៅនេះវិញ?

ថូន : ដឹងអត់ដល់ដែរ អញ្ចឹងមិនដឹងជាសភាពការណ៍គេយ៉ាំងម៉េច អត្ថភាពខ្ញុំមិនដឹងយ៉ាំងម៉េចបានគេបញ្ជូនម៉ោនេះអត់ដឹងទំនាស់ វាមានទំនាស់គ្នាខាងនោះពួកខ្មែរនោះ អត្ថភាពខុសគ្នា ។

ដានី : អត្ថភាពច្រើនទេ?

ថូន : ច្រើនអត្ថភាព ដល់អញ្ចឹងវាអត់ត្រូវគ្នា អ្នកដែលធ្លាប់នៅភ្នំពេញជាមួយគ្នាគេនៅនេះដ៏អញ្ចឹងមានតែកងពួកខ្ញុំ ហើយ ឈឹម មន្នី នេះគាត់នៅនេះ ដល់អញ្ចឹងគេថាពិបាកត្រូវគ្នាគេដកម៉ោនៅជុំគ្នានៅនេះ ដ៏អញ្ចឹងមូលម៉ាកងវរៈខ្ញុំ ។

ដានី : ម៉ោកន្លែងនេះដំបូងគេហៅអីគេ?

ថូន : នេះ?

ដានី : បាទ!

ថូន : នេះគេហៅភូមិដូង ។

ដានី : ដំបូងគេហៅភូមិដូងម៉ង?

ថូន : បាទ!

ដានី : គេអត់ហៅម៉ាឡៃទេ?

ថូន : ទេ! មុនដំបូងអត់ទាន់ហៅម៉ាឡៃទេ ម៉ាឡៃនេះគេអត់ទាន់ហៅទេ ដល់ក្រោយមកទៀតទេបានគេដាក់ឈ្មោះ ភ្នំម៉ាឡៃ បានមានឈ្មោះ មុនដំបូងគេហៅភូមិដូង ។

ដានី : ម៉េចបានគេហៅភូមិដូង?

ថូន : ទេ! ភូមិថៃ គេដាក់ណាំងពី ដល់អញ្ចឹងយើងជាប់ហៅភូមិដូងតែម្តងទៅ ។

ដានី : ណាំងពីហ្នឹងភាសាថៃគេហៅថាដូង?

ថូន : មិនដឹងយ៉ាំងម៉េចខ្ញុំមិនដឹងដែរ ។

ដានី : អញ្ចឹងដំបូងគេហៅភូមិដូង?

ថូន : បាទ!

ដានី ៖ សុទ្ធតែកងទ័ពទាំងអស់?

ថូន ៖ សុទ្ធតែកងទ័ពទាំងអស់ គ្រួសារមួយៗ អត់សូវមានគ្រួសារទេ សុទ្ធតែនៅលីវ មានៗតិច ។

ដានី ៖ សុទ្ធតែប្រុសៗឬមានស្រីដែរ?

ថូន ៖ មានស្រីៗកងដឹកជញ្ជូន ។

ដានី ៖ នៅក្នុងកងទ័ពឬក៏ដាច់កងដឹកជញ្ជូនហ្នឹង?

ថូន ៖ កងដឹកជញ្ជូនដូចថាកងទ័ពគេទៅនៅខាងមុខទៅ កងដឹកជញ្ជូនទៅនៅក្រោយ កងដឹកជញ្ជូនមានប្រុសដែរ សម្រាប់ដឹកជញ្ជូនយកទៅឲ្យទ័ព ។

ដានី ៖ បាទ!

ថូន ៖ បាទ!កាលនោះនៅកន្លែងនេះមានដីរ៥ក្បាលសម្រាប់ដឹកជញ្ជូន ។

ដានី ៖ ដីរ៥ក្បាល?

ថូន ៖ បាទ!ដីរ៥ក្បាលសម្រាប់ដឹកជញ្ជូន ។

ដានី ៖ ដីរហ្នឹងម៉ោពីណាម៉ោ ដីរនៅក្នុងព្រៃហ្នឹងឬគេយកពីណាម៉ោ?

ថូន ៖ ដីរស្រុកយកមកពីក្នុងម៉ោ រត់ចេញម៉ោនោះ ។

ដានី ៖ អ្ហូ!រត់ចេញម៉ោយកដីរម៉ោតាម?

ថូន ៖ បាទ!យកដីរបើកផ្លូវម៉ោតាម ដីរទេអ្នកបើកផ្លូវទេកាលហ្នឹង ។

ដានី ៖ ដីរហ្នឹងបាត់ មកដល់សព្វថ្ងៃហ្នឹងនៅដែរឬអត់?

ថូន ៖ ខ្ញុំអត់ដឹងដែរ មិនដឹងក្រោយមកទៀតទៅណាទៀត បាត់ទៅណាខ្ញុំអត់ដឹង ។

ដានី ៖ បាត់តាំងពីឆ្នាំណាម៉ោ?

ថូន ៖ បាត់តាំងពីឆ្នាំ៨២ ។

ដានី ៖ អ្ហូ!យូរហើយ?

ថូន ៖ បាទ!ថៃលួចផង ថៃលួចអស់មួយដល់ក្រោយមកទៀតមិនដឹងយ៉ាងម៉េចខ្ញុំអត់ដឹង ។

ដានី ៖ ចុះអ៊ើ!ពេលហ្នឹងយ៉ាងម៉េចពូអាចចាំពេលដែលពូមកដល់ដំបូង ដូចថាដំបូងយើងមានកងដឹកជញ្ជូននឹងកងទ័ព កងទ័ពនៅខាងមុខ កងដឹកជញ្ជូននៅខាងក្រោយមិនចឹង?

ថូន ៖ បាទ!

ដានី ៖ កាលហ្នឹងយើងរៀបយ៉ាងម៉េច កងទ័ពមានគេរៀបយ៉ាងម៉េច កងដឹកជញ្ជូនយ៉ាងម៉េចទៅ?

ជូន ៖ កងទ័ព ឧទាហរណ៍ថាមាកងវរៈមានគ្នា២០០នាក់ ១០០នាក់ទៅប្រចាំការនៅខាងមុខ ១០០នាក់នៅខាងក្រោយនៅតាមកន្លែងនៅព្រំដែន ធ្វើជុំធ្វើអីរហូតទៅដល់ខ្លាំងរាប់នោះ ។

ដានី ៖ បាទៗ!

ជូន ៖ ដល់អញ្ចឹង១០០ទៅប្រចាំការនៅក្នុង ១០០នៅស្នាក់ការភូមិ ហើយត្រូវការដឹកជញ្ជូនក៏រើសទ័ពទៅដឹកជញ្ជូនទៅ កន្លះខែឬមួយខែ ដូរគ្នាម្តង ។

ដានី ៖ ចុះនៅនេះអ៊ីជាកងពលដែរឬអត់ទេ?

ជូន ៖ ជាកងពលដែរ កងពលហ្នឹងមាន សូរ ហុង ។

ដានី ៖ សូរ ហុង ហ្នឹងគាត់កាន់កងពល?

ជូន ៖ បាទៗ!

ដានី ៖ ចុះខាងដឹកជញ្ជូនពីណាគេអ្នក?

ជូន ៖ ដឹកជញ្ជូនកាលនោះគ្រប់គ្រងដោយគាត់ដែរហ្នឹង ទាំងអស់រួមមាកងពលហ្នឹង ប៉ុនមានប្រធានតាមផ្នែកៗកងវរៈ មាន រ៉េន នោះផុះនេះ ។

ដានី ៖ ផុះគាត់នេះ?

ជូន ៖ បាទ!

ដានី ៖ គាត់វរៈ?

ជូន ៖ បាទ!គាត់គ្រប់គ្រងពួកកម្លាំងដឹកជញ្ជូន ។

ដានី ៖ គាត់គ្រប់គ្រងពួកកម្លាំងដឹកជញ្ជូន?

ជូន ៖ បាទ!

ដានី ៖ ផុះគាត់មួយ?

ជូន ៖ នោះផុះគាត់នោះអាខ្ពស់នោះ ។

ដានី ៖ បាទ!ហើយតាភាព?

ជូន ៖ តាភាពហ្នឹងបើនិយាយទៅ ក្រោម ហុងទេ ដល់ពេលក្រោយមកទៀត បងហុងគាត់ផ្លាស់ទៅនៅភ្នំឆត្រ ដល់អញ្ចឹងឡើង ពូភាពគាត់គ្រប់គ្រងនៅនេះរួមម៉ាកងពល ។

ដានី ៖ កងពលលេខប៉ុន្មានកាលហ្នឹង?

ជូន ៖ កងពលប៉ុន្មានទេ កងពល៤៥០ភ្លេចហើយយូរពេក ។

ដានី ៖ ចុះកាលហ្នឹងពូអាចរៀបរាប់នៅចាំថាជីវិតពេលហ្នឹងយ៉ាងម៉េចដែរ ជួបប្រទះអីខ្លះ ហើយការរស់នៅយ៉ាងម៉េចដែរ?

ជូន ៖ បើនិយាយជីវិតកាលហ្នឹង បើនិយាយពីទ័ពហ្នឹងវាទៅវៃអត់មាននឹកឃើញអីទេ អញ្ចឹង ការរកស៊ីនៅក្រោយដូចថាវាអត់មានសល់នឹង ដល់អញ្ចឹងនឹងឃើញថាហ៊ឹមិនដឹងស្លាប់ថ្ងៃណា ដល់អញ្ចឹងពេលទៅប្រចាំការ ទៅវៃទៅអីហ្នឹងដល់អញ្ចឹងគិតតែម៉ាសប្បាយៗ ការរស់នៅវាមិនមាននឹកឃើញថា រស់បានយូរទេ ។

ដានី ៖ យើងវៃគ្នារាល់ថ្ងៃ ឬយូរៗវៃមួយដង?

ជូន ៖ បើនិយាយពីទៅប្រចាំការវៃគ្នារាល់តែថ្ងៃ មួយថ្ងៃជួនកាល២ដង ៣ដង ។

ដានី ៖ យើងទៅវៃគេ ឬខាងក្នុងនោះគេវៃម៉ោ?

ជូន ៖ វាអត់ទៀង ជួនកាលបើថាទាហានក្នុងឡើងម៉ោក៏វៃ បើអត់ទេក៏ឡើងទៅវៃ ។

ដានី ៖ អ្ហូ!អញ្ចឹង?

ជូន ៖ បាទ!អត់ទៀង ។

ដានី ៖ ចុះការហូបចុកអីយ៉ាងម៉េច គ្រប់គ្រាន់ឬយ៉ាងម៉េច?

ជូន ៖ ការហូបចុកអត់គ្រប់គ្រាន់ទេ ជួនក៏ហូបគ្រប់គ្រាន់ តែបើនៅក្រោយហូបគ្រប់គ្រាន់ បើទៅមុខជយនកាលខបសគ្គតាមផ្លូវទឹកឡើង ខែវស្សាទឹកឡើងដឹកជញ្ជូនទៅមិនរួច អញ្ចឹងទៅហូបបបរទៅ ។

ដានី ៖ បើយើងនៅក្រោយ យើងអត់ទៅសមរភូមិនៅខាងមុខនេះហូបគ្រប់គ្រាន់?

ជូន ៖ បាទ!គ្រប់គ្រាន់ ។

ដានី ៖ ចុះយើងបានមកពីណាដូចអង្ករ ដូចម្ហូបអី?

ជូន ៖ ដឹកយកពីថៃម៉ោ ។

ដានី ៖ យើងយ៉ាងម៉េច យើងទៅទាក់ទងយ៉ាងម៉េច?

ជូន ៖ ទាក់ទងខ្ញុំអត់ដឹងទេ មិនដឹងយ៉ាងម៉េចខាងគេទំនាក់ទំនងម៉េចខ្ញុំអត់ដឹងដែរ ឃើញតែ បានម្ហូប អង្ករ ត្រីខ ត្រីស្ងួត យកមកទាំងកញ្ចេរ ប្រហុកអីហ្នឹង ។

ដានី ៖ មិនខ្វះទេ?

ជូន ៖ បាទ!

ដានី ៖ ចុះផ្ទះសម្បែងកាលហ្នឹងធ្វើទៅ?

ជូន ៖ អាស្រ័ កូនឈើអីកាប់ធ្វើ ប្រកស្បូវតូចៗម៉ាក្រុម ២-៣ខ្ទង់អីស្រេចតែអ្នក ឧស្សាហ៍ ។

ដានី ៖ ធ្វើទាបៗ ឬធំៗ ?

ថូន ៖ ធ្វើទាបៗ ដូនកាលធ្វើទាមដាក់គ្រែ ។

ដានី ៖ អត់មានផ្ទះធំៗទេ?

ថូន ៖ អត់ទេៗ អត់មានទេ

ដានី ៖ កាលហ្នឹងផ្ទះធ្វើនៅហ្នឹងដែរ ឬនៅណា?

ថូន ៖ នៅតាមដួរមាត់អូររហូត

ដានី ៖ យើងធ្វើនៅតែមាត់អូរទេ?

ថូន ៖ វាស្រួលម្យ៉ាងមានទឹក ម្យ៉ាងឆ្ងាយខ្លាចពេលយួនវ៉ៃអីពិបាក ជិតអូរចុះចូលទៅដីថៃម៉ង

ដានី ៖ កាលនោះនៅភូមិហ្នឹងវាលអញ្ចឹងឬសុទ្ធតែព្រៃ?

ថូន ៖ សុទ្ធតែព្រៃទាំងអស់ ព្រៃឬស្សីទាំងអស់ ដើមឈើធំៗណាស់ដើមម៉ៅអោបៗ ទើបតែវាលម៉ៅកាលឆ្នាំ៨៥-៨៦ចាប់ផ្ដើមវាលបណ្ដើរៗហើយ ។

ដានី ៖ ម៉េចបានវាល?

ថូន ៖ យើងចេះតែកាប់នៅអញ្ចឹងទៅ ។

ដានី ៖ ដើមឈើធំៗទៅកាប់?

ថូន ៖ យើងកាប់យើងអារ ថៃចូលទិញ កាប់យកលក់ឲ្យថៃ ។

ដានី ៖ អញ្ចឹងកាលជំនាន់ហ្នឹងកាលពីឆ្នាំ៨០ នៅហ្នឹងរហូតម៉ងឬក៏មានផ្លាស់ប្ដូរអីទៀត?

ថូន ៖ អត់មានរត់ទេ!តែគ្រាន់មានផ្ទើរបន្តិចបន្តួច អត់មានរត់ចេញពីផ្ទះទេ គ្រាន់តែផ្ទើរបន្តិចកាលគេផ្ដាច់ខ្ទួននោះ ។

ដានី ៖ ប៉ុន្តែមុនដូចថាពេលដែលឆ្នាំ៨០ យើងនៅហ្នឹងយើងឡើងទៅមុនទៅអី ក្រោយម៉ោមានកងទ័ពខាងក្នុងមានដែលចូលមកដល់ហ្នឹងដែរឬអត់?

ថូន ៖ អត់ដែលដល់ទេ អ៊ូ!ដល់ម្ដងដល់រត់ទៅនៅថៃ រត់ទៅនៅគេហៅ៨៥ នៅក្នុងដីថៃ ។

ដានី ៖ ទៅនៅយូរដែរ?

ថូន ៖ នៅរហូតមកទល់ឆ្នាំ៩០ បានមកនៅនេះវិញ ។

ដានី ៖ អញ្ចឹងទៅនៅដីថៃយូរដែរ?

ថូន ៖ បាទ!យូរដែរ ។

ដានី ៖ ៤-៥ឆ្នាំដែរ?

ថូន ៖ បាទ!

ដានី ៖ ចុះដល់ពេលទៅនៅដីថៃពូទៅនៅដីថៃដែរ?

ថូន ៖ ទៅកាលហ្នឹងខ្ញុំអត់ទាន់មានគ្រួសារទេ ។

ដានី ៖ អត់ទាន់មាន?

ថូន ៖ នៅ ខ្ញុំទើមបានឆ្នាំ៩១-៩២នេះ ។

ដានី ៖ អ្ហូ!អញ្ចឹង កាលហ្នឹងពូនៅលីវរហូត?

ថូន ៖ បាទ!

ដានី ៖ កាលហ្នឹងពូរៀបការពូអាយុប៉ុន្មានដែរអញ្ចឹង?

ថូន ៖ ខ្ញុំ៣៣-៣៤ហើយ ។

ដានី ៖ ហើយកាលហ្នឹងជួបប្រពន្ធពូគាត់ធ្វើអីគេកាលហ្នឹង?

ថូន ៖ នៅខាងក្នុងទេ ខ្ញុំទៅប្រចាំការនៅហ្នឹងជួបគេមករកអីៗនៅក្នុង ច្រូតស្រូវច្រូតអីហ្នឹងក៏ជួបគ្នានៅក្នុង ។

ដានី ៖ ជួបហើយក៏នាំមកនេះ?

ថូន ៖ បាទ!

ដានី ៖ គាត់ចង់ម៉ោ?

ថូន ៖ បាទ!

ដានី ៖ គាត់នៅស្រុកណា?

ថូន ៖ នៅចំណោមរោងគោនេះណា៎ ប៉ុនមិនដឹងស្រុកស្អី នៅបន្ទាយមានជ័យយើងនេះ ។

ដានី ៖ ជួបគាត់ទៅច្រូតស្រូវ?

ថូន ៖ បាទ!

ដានី ៖ យើងជួបនឹងយ៉ាងម៉េចបានគាត់ស្មក្រចិត្តម៉ោជាមួយពូ?

ថូន ៖ ជួបទៅក៏ទាក់ទងគ្នាសួរចេះសួរចុះ ។

ដានី ៖ តែម្នាក់គាត់ឬក៏មានគ្នាច្រើន?

ថូន ៖ អ្ហូ!ច្រើន អ្នកនៅតាមនេះបានអ្នកនៅម្តុំហ្នឹងច្រើនណាស់ ។

ដានី ៖ អ្ហូ!

ថូន ៖ ចុះទ័ពកាលនោះសុទ្ធតែនាក់មិនទាន់មានគ្រួសារទេ សុទ្ធតែនាក់នៅលីវទាំងអស់ ។

ដានី ៖ អញ្ចឹងកាលពូទៅនៅដីថៃឆ្នាំ៨៥ហ្នឹង យើងអត់ដែលចូលម៉ោទេ? រហូតដល់ឆ្នាំ៩០?

ថូន ៖ អត់ទេ!ទៅនៅនោះជួនកាលទៅសម្រាកបានតែកន្លះខែទេ ចេញម៉ោវិញហើយ ។

ដានី ៖ ចេញមកធ្វើអី?

ថូន ៖ ចេញទៅវ៉ៃនៅខាងក្នុង ទៅប្រចាំការនៅក្នុង ។

ដានី ៖ ចេញពីដីថៃមកវ៉ៃវៀតណាម?

ថូន ៖ បាទ!

ដានី ៖ ប៉ុន្តែកន្លែងនេះខាងក្នុង?

ថូន ៖ បាទ!ខាងក្នុងទាហានរដ្ឋាភិបាលម៉ោ ។

ដានី ៖ ខាងយួនហើយនឹងរដ្ឋកម្ពុជាគេនៅហ្នឹង?

ថូន ៖ បាទ!នៅតាម ។

ដានី ៖ អញ្ចឹងយើងទៅវ៉ៃពីក្នុងមមកវិញ?

ថូន ៖ បាទ!ស៊ើបរកន្លែងស្ងាត់ចេញទៅ ជួនក៏ផ្ទុះមីនទៅក៏អត់បានចេញទៅ បកទៅវិញទៅ បើអត់ផ្ទុះមីនទេ ឆ្លងបានក៏ចេញទៅនៅមុំប៉យគគរសាយមន ។

ដានី ៖ រហូតដល់ឆ្នាំ៩០ បានយើងចូលមកហ្នឹងវិញ?

ថូន ៖ បាទ!

ដានី ៖ យ៉ាងម៉េចបានដល់ឆ្នាំ៩០ យើងចូលមកនេះវិញ?

ថូន ៖ កាលហ្នឹងទាហានខាងក្នុងនៅតាមភ្នំ តាមនេះដូចថាអត់ទឹកអត់អីដល់អញ្ចឹងចូលវ៉ៃរត់ទៅ បានមកនៅនេះវិញ ។

ដានី ៖ ចុះពេលដែលយើងមកនៅនេះវិញ យើងមានបានជួបប្រទះផលវិបាកអ៊ីទៀតប្តអត់ ពេលឆ្នាំដែលយើងចូលមកនៅដំបូង?

ថូន ៖ រឿងពិបាកៗត្រង់ថាដែលចូលមកនៅកន្លែងតាមបន្ទាយសុទ្ធតែមីន ។

ដានី ៖ សុទ្ធតែមីន?

ថូន ៖ បាទ!

ដានី ៖ មីនយ៉ាងម៉េចមីនខាងក្នុងគេជាអ្នកដាក់ឬយ៉ាងម៉េច?

ថូន ៖ ចំរុះ ជួនកាលទ័ពព្រៃក៏ដាក់ ទ័ពក្នុងក៏ដាក់ ដល់អញ្ចឹងវាសុទ្ធតែមីន តាមមាត់អូរក៏សុទ្ធតែមីន ។

ដានី ៖ សុទ្ធតែមីនអញ្ចឹងធ្វើម៉េចទៅអញ្ចឹង?

ថូន ៖ រាវ

ដានី ៖ រាវដោយខ្លួនឯង?

ថូន ៖ បាទ!ម្ចាស់ការរៀនខ្លួនទៅ ដីអ្នកណាអ្នកនោះរាវទៅ ។

ដានី ៖ ចុះកលហ្នឹងមានគ្រោះថ្នាក់ច្រើនប្អត់?

ថូន ៖ ច្រើន!ស្លាប់ ពិការដាច់ជើងដាច់ដៃច្រើនណាស់តាមនេះ ។

ដានី ៖ ដោយសារមីន?

ថូន ៖ បាទ!ដោយសារមីននៅតាមព្រំដែន ។

ដានី ៖ កាលពីសង្គ្រាមកាលពីឆ្នាំ៨០ អត់សូវមានពិបាកទេ?

ថូន ៖ មានច្រើនដូចគ្នា ចុះបើទៅវៃគ្នានោះដាក់មីនខ្លួនឯង ជួលកាលដើរទៅទាក់ខ្លួនឯង ក៏មាន ។

ដានី ៖ អ្ហូ!អញ្ចឹង?

ថូន ៖ ពិការ ស្លាប់ៗ ។

ដានី ៖ កាលយើងចូលម៉ោពីឆ្នាំ៩០ ហ្នឹង ចិត្តយើងយ៉ាងម៉េចខុសប្លែកពីឆ្នាំ៨០ យ៉ាងម៉េច?

ថូន ៖ បើនេះទៅវាដូចតែគ្នា ដូចគ្នាត្រង់ថាកន្លែងដែលធ្លាប់នៅ ។

ដានី ៖ កន្លែងដែលធ្លាប់នៅយើងមកនៅកន្លែងដដែលវិញ?

ថូន ៖ បាទ!ទាក់ទងថៃអីតាមធម្មតា ។

ដានី ៖ បាទ!យើងចូលម៉ោ យើងដោះមីនធ្វើអី ធ្វើផ្ទះធ្វើអីនៅទៅ?

ថូន ៖ បាទ!

ដានី ៖ កាលហ្នឹងពូអត់ទាន់មានគ្រួសារទេ?

ថូន ៖ នៅ

ដានី ៖ ចុះបើអត់ទាន់មានអញ្ចឹងយើងធ្វើផ្ទះនៅដែរឬក៏អត់ទេ?

ថូន ៖ អត់ទេ!នៅតាមផ្ទះអ្នកដែលគេមាន នៅកងចល័តជាមួយគ្នា ក្រុមជាមួយគ្នា រហូតដល់យើងសមាហរណកម្មហើយមានកាប់ពិកាលអីធំល្ហឹងល្ហើយទៅក៏វាលអស់ទៅ ។

ដានី ៖ ចុះពូមានគ្រួសារឆ្នាំ៩២?

ថូន ៖ បាទ!

ដានី ៖ ពេលហ្នឹងពូមករៀបការនៅណា?

ថូន ៖ នេះនៅផ្ទះមុខនេះ ហើយបានមកធ្វើផ្ទះនៅនេះ ។

ដានី ៖ ពេលពូរៀបការហើយ ពូនៅធ្វើកងទ័ពដដែល?

ថូន ៖ ដដែល ។

ដានី ៖ ចុះប្រពន្ធពូ?

ជូន ៖ នៅផ្ទះ ។

ដានី ៖ កាលហ្នឹងយើងអត់ទាន់មានចំការមានស្រែទេ?

ជូន ៖ នៅ គេអ្នកមានៗមានខ្លះហើយ ។

ដានី ៖ ចុះកាលហ្នឹងយើងមានអីសម្រាប់ហូបចុក មានរបប ឬក៏យ៉ាងម៉េច?

ជូន ៖ របបបើក អង្ករ ត្រីខ ហើយរកបាន អាលឈើលក់ឲ្យថៃ ។

ដានី ៖ កាលហ្នឹងនៅធ្វើកងទ័ពដដែលយើងអាចអាលឈើលក់បានដែរ?

ជូន ៖ បាន អាលលក់ឲ្យថៃ ។

ដានី ៖ អញ្ចឹងពីណាអាលបានប៉ុន្មានលក់បាន បានលុយខ្លួនឯងទៅ?

ជូន ៖ បាទ!

ដានី ៖ អ្នកអាលបានច្រើន លក់បានច្រើន អ្នកណាបានអាលបានតិច លក់បានតិច?

ជូន ៖ បាទ!

ដានី ៖ គេអត់លក់ទាំងមូលទេ ហើយចាំចែកលុយគ្នាទេ?

ជូន ៖ ទេ! បើធ្វើមានក្រុម មានអង្គភាពបានអញ្ចឹង បើធ្វើតាមបុគ្គលយើងបានចំណែកតូចៗ អ្នកកាប់ឈើរួម មានអង្គភាព មានមេរួមអញ្ចឹងបានម៉ោចែកលុយគ្នាទៅ ឡានថៃមក ដឹក កាលមិនទាន់លដ្ដាច់ខ្លួនអត់ទេ រកបានបន្តិចៗទេ គ្មានថៃចូលបានច្រើនទេ បាន ដឹកអាលជាសន្លឹកតូចៗ ២-២៣សន្លឹកទេ ។

ដានី ៖ ចុះដល់ពេលពូដឹងទេជិតសមាហរណកម្មហើយយ៉ាងម៉េចដែរ?

ជូន ៖ ខ្ញុំដឹងអត់ដល់ដែល ស្រាប់តែទៅប្រចាំការទៅដល់ក្រោយមកទៀតពូគេថាបេះថាចុះ អារឿងអិះតាត្បូង អិះតាត្បូវគេថាពួកម៉ាខ្មៅគេថាពួកស៊ីសុផុនខាងដើងសុទ្ធតែពួក ប៉ារ៉ា ។

ដានី ៖ ប៉ារ៉ាម៉េចទៅ?

ជូន ៖ ចុះកាលហ្នឹងពួកប៉ារ៉ារដ្ឋាភិបាលមិនចូលគ្នាកាលហ្នឹង ។

ដានី ៖ បាទ!

ជូន ៖ ដល់អញ្ចឹងគេថានេះចូលប៉ារ៉ាដែរ ដល់អញ្ចឹងគេថាប៉ារ៉ាចូលពេញហើយកងពលម៉ាខ្មៅ ដល់អញ្ចឹងរកវៃគ្នាមួយសារទៀត ។

ដានី ៖ រកវៃជាមួយពួកណា?

ជូន ៖ ពួកខាងត្បូង ។

ដានី ៖ ខាងត្បូងណា?

ថូន ៖ ពួកកងពលផ្សេង ពួកកងពលតាពុធ ។

ដានី ៖ យើងនៅម៉ាឡៃ ពួកគាត់នៅខាងណា?

ថូន ៖ នៅសំពៅលូន ។

ដានី ៖ រកវៃគ្នា?

ថូន ៖ បាទ!កងពលខុសគ្នាទេ យើងថាចេះថាចុះទៅរកវៃគ្នា ហើយដល់ក្រោយមកទៀតទៅមិនដឹងយ៉ាងម៉េចក៏ត្រូវគ្នា លែងអីទៅក៏ផ្តាច់ខ្លួនទាំងអស់គ្នាទៅ ។

ដានី ៖ ចុះពេលដែលផ្តាច់ខ្លួនហ្នឹង យើងយ៉ាងម៉េចយើងមានភូមិឈ្មោះភូមិស្រុកអី កាលពីជំនាន់មុនផ្តាច់ខ្លួនយើងមានឈ្មោះភូមិ ស្រុក ដែរឬអត់ទេ?ដូចឥឡូវមានភូមិថ្មី ភូមិកណ្តាល ភូមិវត្តចាប ឬក៏ឃុំម៉ាឡៃអីអញ្ចឹងទៅអាហ្នឹងគេទើបបង្កើតក្រោយឬអត់ទេ?

ថូន ៖ ទើបបង្កើតក្រោយៗដែលសមាហរណកម្មហើយ ដែលចែកជាក្រុម ជាពួក មានការរៀបចំមកពីលើ ។

ដានី ៖ ពីលើណាមៅ?

ថូន ៖ កាលដែលរដ្ឋាភិបាលចូលមកនេះ សម្តេចនាយកចូលមកភូមិដូងនេះនោះ!

ដានី ៖ បាទ!

ថូន ៖ រើសចាត់តាំងជាស្រុកទៅ ជាភូមិ ជាឃុំទៅ ដល់អញ្ចឹងទៅគេរៀបចំតាមហ្នឹងទៅមានភូមិថ្មី ភូមិម៉ាឡៃអញ្ចឹងទៅ ។

ដានី ៖ បាទ!កាលពីមុនអត់មានទេអត់មានឈ្មោះអញ្ចឹងទេ?

ថូន ៖ អត់ទេ!

ដានី ៖ ចុះដឹងថាម៉េចបានគេដាក់ឈ្មោះអញ្ចឹងៗដែរឬអត់ ដូចឈ្មោះភូមិថ្មី ភូមិអីៗហ្នឹងម៉េចបានគេដាក់អញ្ចឹង?

ថូន ៖ អត់ដឹងដែរ ខាងស្រុក ខាងភូមិគេដាក់ខ្ញុំអត់ដឹងដែរ ។

ដានី ៖ ចុះបន្ទាប់ពីយើងធ្វើសមាហរណកម្មហើយ យើងផ្លាស់ប្តូរពីការរស់នៅខុសពីមុនយ៉ាងម៉េចខ្លះទៅ?

ថូន ៖ ខុសពីមុនត្រង់ថា វាដើរហើរទៅបានឆ្ងាយ ។

ដានី ៖ បាទ!ខ្ញុំចង់ដឹងចេះ ចង់ថាកាលពីពូនៅកងទ័ព ដូចថាពូក្រុមគ្រួសារប្រពន្ធអីយ៉ាងម៉េចយើងត្រូវធ្វើអីខ្លះ ពេលសមាហរណកម្មហើយយើងដូច ថាក្រុមគ្រួសារយើងយ៉ាង ម៉េចយើងត្រូវធ្វើអីៗខុសពីមុនម៉េច?

ថូន ៖ ខុសគ្នាត្រង់ថា ការរកស៊ីវាអត់សូវមានទេពីមុន ចុះគិតតែសង្រ្គាម ដល់ក្រោយមកទៀតការរកស៊ីបានទូលំទូលាយ យើងរកស៊ីបានតាមចិត្ត ។

ដានី ៖ ចុះដូចផ្ទះសម្បែង ដីធ្លីអី កាលពីមុនមានដែរឬអត់?

ថូន ៖ អត់មានទេ!

ដានី ៖ ចុះដីធ្លីផ្ទះសម្បែងអីដឹងសមាហរណកម្មហើយគេចែកឲ្យឬក៏យើងចាប់ដោយខ្លួនឯង?

ថូន ៖ គេចែក ដូវនេះគេចែក គេចែកបួន៍ៗហើយយើងនៅ ។

ដានី ៖ ចុះដីស្រែចំការ?

ថូន ៖ ដីស្រែចំការកាប់ខ្លួនឯង កាប់បានប៉ុន្មានយកប៉ុណ្ណឹង តាមកម្លាំងយើងប្រឹងបាន ។

ដានី ៖ ពូកាប់បានប៉ុន្មានដែរ?

ថូន ៖ ខ្ញុំបានតែដីស្រែ ៨រៃ ។

ដានី ៖ ៨រៃហ្នឹងកាប់ខ្លួនឯងដែរ?

ថូន ៖ បាទ!

ដានី ៖ ៨រៃប៉ុន្មានហិចតា?

ថូន ៖ ១ហិចតាជាង មិនដល់កន្លះផង ។

ដានី ៖ អញ្ចឹងក្រោយពីសមាហរណកម្មហើយដូចថាពូធ្វើតែស្រែទេ?

ថូន ៖ បាទ!ធ្វើតែស្រែ ។

ដានី ៖ អត់មានធ្វើអីទៀតទេ?

ថូន ៖ អត់ទេ!ក្រោយមកទៀតខ្ញុំធ្វើ ខ្ញុំទឹមឈប់ធ្វើទ័ពទេ ទៅប្រចាំការនៅព្រះនេត្រព្រះ ខ្ញុំទឹមឈប់ទេ ។

ដានី ៖ ឈប់ដាច់ពីកងទ័ព?

ថូន ៖ បាទ!

ដានី ៖ តែឥឡូវមានប្រាក់ខែដែរឬអត់ទេ?

ថូន ៖ ឥឡូវអត់មានទេ កាលដំបូងវាយ៉ាប់ពេក កាលនោះប្រាក់ខែវាបានតិច ហើយទៅប្រចាំការនៅឆ្ងាយ មើលទៅកូនប្រពន្ធយ៉ាប់ក៏ឈប់ទៅ ។

ដានី ៖ ចុះពូដូចថាពូធ្លាប់បានឆ្លងកាត់អញ្ចឹងថាតើម៉ាឡៃយើងមានការប្រែប្រួលយ៉ាងម៉េចដែរតាំងពី៨០ពូចូលម៉ោដមបូង ក្រោយម៉ោឆ្នាំ៩៦ពេលសមាហរណកម្មហើយមានការផ្លាស់ប្តូរយ៉ាងម៉េចដែរបើតាមពូជួប ដូចថាធ្លាប់រស់នៅ?

ថូន : ឃើញប្លែកត្រង់ថាមនុស្សវាកាន់តែសំបូរវាធូរធារ រកបាន មានឈ្នួញចូលទិញមាន ការលក់ដូរចេះតែបានទៅ ឃើញប្រជាជនចេះតែមានមុខរបរច្រើន ។

ដានី : ចុះភូមិស្រុកអីក្រោយសមាហរណកម្មហើយមានការផ្លាស់ប្តូរម៉េច?

ថូន : ប្លែកត្រង់ថា ផ្ទះពីមុនតូចៗ ឥឡូវផ្ទះធំៗ មានម៉ូតូមានឡានចង់គ្រប់ផ្ទះ ។

ដានី : ចុះកាលពីមុន?

ថូន : កាលពីមុនម្តុំនេះមានពូណាមានម៉ូតូ មានឡានអត់មានទេ ក្រោយមកទៀតកាន់តែមាន ១ឆ្នាំឡើងបន្តិចៗ ។

ដានី : កាលពីឆ្នាំ៨០ អត់មានទេ?

ថូន : អត់មានទេ!មានតែឡានរដ្ឋឡានចិនជួយនឹង ។

ដានី : អត់មានផ្លូវទេ?

ថូន : មានផ្លូវ ប៉ុន្តែផ្លូវខូច ផ្លូវធម្មតាផ្លូវលើ មានតែអាត្រាក់បើក ។

ដានី : ចុះពូដល់ឆ្នាំណាបានពូបានទៅលេងផ្ទះទៅជួបជុំបងប្អូននៅស្រុកកំណើត?

ថូន : ខ្ញុំឆ្នាំ៩២ កាលដែលអ៊ុន គាត់ចូល ខ្ញុំទៅលេងផ្ទះខែ១២ ។

ដានី : ចុះកាលពីមុនម៉ោពូមានដែលទាក់ទងដំណឹងជាមុនទេ?

ថូន : អត់ដែលទេ ។

ដានី : ដល់ឆ្នាំ៩២ពូទៅ?

ថូន : បាទ!

ដានី : កាលឆ្នាំ៩២យើងអាចចេញចូលខាងក្នុងខាងក្រៅអីបានឬអត់?

ថូន : បានតែបានតែតាមៗដងស៊ីងទេ បានហានចូលព្រោះស្គាល់ប្រធានភូមិ ប្រធានភូមិគេធានាឲ្យចូល ។

ដានី : ចូលទៅលេងផ្ទះបានប៉ុន្មានថ្ងៃ?

ថូន : ខ្ញុំទៅបាន៤-៥ថ្ងៃ ។

ដានី : ហើយទៅរកផ្ទះឃើញដែរ?

ថូន : ឃើញ ។

ដានី : ពូនៅចាំ?

ថូន : បាទ!នៅចាំវាស្រួលចាំវាមានចំណុចស្ពានថ្ម ទៅដល់ឃើញស្ពានថ្មហ្នឹងដើរចូលទៅ ។

ដានី ៖ ចុះពូខ្ញុំចង់ដឹងថាពេលជំបូងដូចថាយើងបែកតាំងពីឆ្នាំ៧០ដាន់រហូតដល់ឆ្នាំ៩២ ពេលពូទៅដល់ផ្ទះដំបូងពូមានអារម្មណ៍យ៉ាងម៉េចដូចថាយើងបែកគ្នាយូរហើយ ពេលដែលជួបបងប្អូនឪពុកម្ដាយដំបូងពូមានអារម្មណ៍យ៉ាងម៉េចដែរកាលហ្នឹង?

ជូន ៖ ទៅដល់ ចុះយើងបែកយូរដែរ ចូលទៅដល់រំភើបដែរបានជួបបងប្អូន បាត់ឪពុកបាត់ ម្ដាយម្ដាយឪពុកខ្ញុំស្លាប់តាំងពីឆ្នាំ៨៦ ។

ដានី ៖ ពេលហ្នឹងបងប្អូនពូគេស្គាល់ដែរឬអត់ ពេលទៅដល់ដំបូង?

ជូន ៖ ពេលហ្នឹងខ្ញុំផ្ញើររូបថតទៅមុន ៣-៤-៥ថ្ងៃ មានគេចេញចូលខ្ញុំផ្ញើររូបថតទៅ ដល់ឃើញស្គាល់គ្នាទៅ ។

ដានី ៖ ហើយចុះពូស្គាល់គេឬអត់?

ជូន ៖ ខ្ញុំអត់ស្គាល់ទេ ២០ឆ្នាំហើយបានអីស្គាល់ធំៗអស់ហើយ ។

ដានី ៖ កាលពីពូបែកគ្នាទៅតូចៗទេ?

ជូន ៖ នៅតូចៗទេ ប៉ុនកូនមីស្រីនោះ ។

ដានី ៖ ដល់ពេលពូទៅឃើញក្រោយធំៗអស់ហើយ មានប្ដីមានប្រពន្ធអស់ហើយ?

ជូន ៖ បាទ!មានអស់ហើយ ។

ដានី ៖ ដល់ពេលអញ្ចឹងមានអារម្មណ៍យ៉ាងម៉េចទៅ ដូចថាយើងបែកគ្នាយូរ ពេលឃើញដំបូងពេលហ្នឹងយ៉ាងម៉េចដែរ ពួកគាត់ជាមួយពូមានអារម្មណ៍ម៉េចទៅ?

ជូន ៖ មានអារម្មណ៍រំភើប ចុះយើងបែកគ្នាយូរហើយ ទៅដល់ផ្ទះកាលហ្នឹងប្អូនខ្ញុំយំដែរ អាខ្លួនឯងនេះក៏យំ ចុះនៅក្នុងសង្រ្គាមរកអីបាន ។

ដានី ៖ ចុះញាតិមិត្តជិតខាងរបស់ពូនៅឯស្រុកបានជួនគ្នាដែរឬយ៉ាងម៉េចដែរ?

ជូន ៖ ទៅដល់ជួបអត់មានស្គាល់គ្នាទាំងអស់ ដូចប្លែកអត់មានស្គាល់អីទេ ខ្ញុំឆ្នាំ៧០ខ្ញុំចេញខ្ញុំនៅតូចដែរ ។

ដានី ៖ កាលហ្នឹងឆ្នាំ៧០ហ្នឹងឪពុកម្ដាយពូក៏ចេញពីស្រុកដែរ?

ជូន ៖ ចេញពីស្រុកទៅនៅស្រុកឆ្ងាយ គាត់ទៅតស៊ូដែរ ។

ដានី ៖ គាត់តស៊ូកាលហ្នឹងគាត់បានធ្វើអី?

ជូន ៖ គាត់នៅក្នុងមន្ទីរ ។

ដានី ៖ មន្ទីរអីគេ?

ជូន ៖ មន្ទីរស្រុក ។

ដានី ៖ ចុះក្រោយៗម៉ោពូមានដែលទៅលេងស្រុកទៀតឬអត់?

ជូន ៖ ទៅខ្ញុំទៅញឹកដែរ ។

ដានី ៖ ប្រហែលប៉ុន្មានដង?

ជូន ៖ ច្រើន៤-៥-៦ដងហើយ ខ្ញុំក៏ទៅ ប្អូនខ្ញុំក៏មកលេង ។

ដានី ៖ ចុះពូមួយទៀតខ្ញុំចង់ដឹងពីអារម្មណ៍របស់ពូ ដូចថាពូចេញពីស្រុកយូរ ពូមកនៅនេះក៏យូរដែរ តាំងពីឆ្នាំ៧០ម៉ោរហូត ដូចថាអារម្មណ៍ដូចថាមនោសញ្ចេតនាពូនៅហ្នឹង ហើយនៅស្រុកកំណើតខុសប្លែកគ្នាយ៉ាងម៉េចដែរ? ដូចថានៅកាលពីក្មេងពូធ្លាប់មានភាពស្និតស្នាលជាមួយបងប្អូន ឪពុកម្ដាយ ដល់ក្រោយម៉ោពូបានបែកពីស្រុកភូមិហ្នឹង យូររហូតដល់ឆ្នាំ៩២បានពូទៅលេងវិញ តែពូនៅនេះយូរដូចថាកាលពីមុនម៉ោយើងម៉ោពីកន្លែងផ្សេងៗមកស្គាល់គ្នានេះ ម៉ោមានភាពស្និតស្នាលជាមួយអ្នកនៅអគ្គភាពជាមួយកងទ័ពយើងមានមនោសញ្ចេតនានេះ អញ្ចឹងពូគិតមើលថាអារម្មណ៍របស់ពូរវាងយើងនៅម៉ាខ្សែហើយនឹងស្រុកកំណើតវាខុសគ្នាយ៉ាងម៉េចទៅ?

ជូន ៖ វាខុសគ្នាត្រង់ថាកាលនៅនោះយើងនៅពីតូច យើងអត់ទាន់ដឹងពីការរកស៊ីនៅតំបន់ នោះដល់យើងមកនៅនេះយើងចេះតែនៅកន្លែងនេះដឹងអញ្ចឹងការផ្លាស់ប្ដូរអារម្មណ៍អត់មានចង់ទៅនៅស្រុកកំណើតទេ ។

ដានី ៖ អត់ចង់ទៅនៅស្រុកកំណើតទេ?

ជូន ៖ បាទ!ព្រោះវាចាល់ ដូចថាវាអត់មានមុខរបរនឹងប្រកប បើយើងធ្លាប់នៅនេះយើងដឹងថាតាកទិចនៅតំបន់នេះ បើទៅដូចវាម៉ាំងៗមិនដឹងទៅធ្វើអី ។

ដានី ៖ ចុះភាពស្និតស្នាលជាមួយបងប្អូន ជាមួយញាតិជិតខាង ជាមួយមិត្តភក្រកាលពីក្មេងៗយើងនៅស្និតស្នាលដដែលឬក៏ខុសពីមុន?

ជូន ៖ វារៀងដាច់ៗរយោល កាលនោះផ្ទះខ្ញុំនៅឆ្ងាយពីគេផង ដល់អញ្ចឹងការរាក់ទាក់ ការស្និតស្នាលនោះអត់មានទេ ។

ដានី ៖ អត់មានទេ?

ជូន ៖ បាទ!ជួបគ្នាតែពេលទៅសាលា បើមកផ្ទះអត់ទេ ។

ដានី ៖ បាទ!ដល់អញ្ចឹងពេលពូទៅវិញពូអត់មានស្គាល់គេ?

ជូន ៖ បាទ!

ដានី ៖ អញ្ចឹងពូទៅដូចជាឃើញមនុស្សថ្មីអញ្ចឹង?

ថូន ៖ បាទ!

ដានី ៖ ចុះអ្នកនៅនេះវិញ?

ថូន ៖ នៅនេះវិញ ធ្លាប់នៅជាមួយគ្នារ កស៊ីក៏ជាមួយគ្នា ធ្វើទ័ពក៏ជាមួយគ្នា ដូច្នេះការរាប់អានវារអូករអើន ។

ដានី ៖ អញ្ចឹងដូចថាពូមានអារម្មណ៍នៅនេះច្រើនជាងនៅស្រុកកំណើត?

ថូន ៖ បាទ!ច្រើនជាង ព្រោះរអូករអើន ការរាក់ទាក់វាប៉ុន្មានឆ្នាំម៉ោវានៅនេះទៅហើយ ដល់ទៅនោះអត់មានអារម្មណ៍អីរាក់ទាក់ជាមួយជិតខាងក៏អត់ បានតែជាមួយបងប្អូន ។

ដានី ៖ បានតែជាមួយបងប្អូនឯង?

ថូន ៖ បាទ!ខ្ញុំទៅលេងផ្ទះអត់ដែលដើរ ។

ដានី ៖ អត់ដែលដើរទេ?

ថូន ៖ អត់ទេ ចុះអត់ស្គាល់ ។

ដានី ៖ ចុះញាតិជិតខាងអី គេឃើញពូអីគេមានអារម្មណ៍ម៉េចដែរ?

ថូន ៖ គេហៅចូលលេងធម្មតា ។

ដានី ៖ ចុះក្នុងចិត្តពូ ពូរស់នៅនេះទៅថ្ងៃអនាគតអីមានសង្ឃឹមអីដែរ?

ថូន ៖ បើក្នុងចិត្តដូចអត់មានសង្ឃឹមអីទេ បើអញ្ចឹងតាមដំណើរប្រចាំថ្ងៃទៅ ហើយស៊ីឈ្នួលគេបន្តិចបន្តួចទៅតាមកម្លាំងដែលធ្វើបាន ទៅថ្ងៃអនាគតដូចអត់មានសង្ឃឹមអីទេ ព្រោះអត់មានមុខរបរអីវាធំដុំនឹងគេ ។

ដានី ៖ មួយទៀតបើតាមចិត្តរបស់ពូវិញ ពូគិតថាតាំងពីសមាហរណកម្មហើយពូមានការរកស៊ីកាលពីមុនមានរបបគេចែកឲ្យ តើមួយណាស្រួលជាង?

ថូន ៖ ធម្មតាបង បើយើងសង្ឃឹមរបស់គេ វាមិនស្រួលដូចរបស់ខ្លួនឯទេ បើបានមែនតែ បានតិចហូបអត់គ្រប់គ្រាន់ទេ បើដូចឥឡូវវិញយើងចង់រកបានប៉ុន្មានហូបប៉ុន្មានក៏បានតាមចិត្តយើង ។

ដានី ៖ កាលនោះបើគេបើកឲ្យប៉ុន្មានយើងបានហូបតែប៉ុណ្ណោះទេ?

ថូន ៖ បាទ!គេមិនបើកឲ្យយើងសំបូងគ្រប់គ្រាន់ណា៎ បានម៉ារស់ៗ ។

ដានី ៖ ចុះបើចិត្តពូៗគិតថាយើងរស់នៅដោយខ្លួនឯងស្រួលជាង?

ថូន ៖ យើងរស់នៅដោយខ្លួនឯងស្រួលជាងបើបានមិនបានអីវាតាម កម្លាំងយើង ។

ដានី ៖ ចុះកូនៗពូ ពូចង់ឲ្យកូនៗរៀនតទៅមុខបានច្រើន ឬក៏ឲ្យគេមកជួយពូ?

ថូន ៖ បើជាគំនិតរបស់ខ្ញុំចង់ឲ្យតែកូនរៀន តែតាមលទ្ធភាពដែលខ្ញុំប្រឹងទៅរួច បើថាប្រឹងទៅរួចក៏រិតណាឲ្យវារៀនបានក៏រិតហ្នឹង វាថាប្រឹងមិនរួចហើយហ្នឹងមិនដឹងថាម៉េច ។

ដានី ៖ បាទ! ម៉េចបានពូចង់ឲ្យកូនរៀនបានច្រើន?

ថូន ៖ មូលហេតុដែលចង់ឲ្យកូនរៀនច្រើនកុំឲ្យវាល្ងង់ដូចពុក បើពុកវាមិនចេះទៅហើយ ។

ដានី ៖ ដូចថាផលវិបាកនៃការអ្នកមិនចេះអក្សរនឹងអ្នកចេះអក្សរខុសគ្នាម៉េចទៅ?

ថូន ៖ ខុសគ្នាត្រង់ថាអ្នកចេះគេធ្វើអីក៏លឿន ធ្វើអីក៏វាចំរើន បើអ្នកមិនចេះធ្វើអីក៏ទៅមិនបានឆ្ងាយ ធ្វើអីក៏មិនចំនេញអ្នកមិនចេះ ។

ដានី ៖ ពូគិតអញ្ចឹង?

ថូន ៖ បាទ! ផលវិបាកសម្រាប់អ្នកមិនចេះឆាប់ ធ្វើអីក៏មិនលឿនដូចគេ ។

ដានី ៖ មួយទៀតចុងក្រោយទាក់ទងពីតុលាការ ដែលគេបង្កើតកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមសព្វថ្ងៃហ្នឹងពូមានដែលព្ធមានដែលដឹងដែរឬអត់?

ថូន ៖ ធ្លាប់ព្ធ បានមើលដែរ ។

ដានី ៖ ពូឧស្សាហ៍មើលដែរ?

ថូន ៖ មើលបានម្តងៗពេលដែលទំនេរ ។

ដានី ៖ មើលឃើញម៉េចខ្លះពេលដែលគេកាត់ទោសម៉េចខ្លះ?

ថូន ៖ ទេខ្ញុំមើលឃើញតែគេកាត់ទោសតាឌុច ។

ដានី ៖ ពូស្គាល់ឌុច ដែរឬអត់?

ថូន ៖ អត់ដែលស្គាល់ទេ ឃើញតែក្នុងទូរទស្សន៍ហ្នឹងឯង ។

ដានី ៖ ចុះគាត់ធ្វើអីពេលគេកាត់ទោស?

ថូន ៖ គាត់មេគុក ។

ដានី ៖ ចុះបើតាមពូវិញពូយល់ឃើញម៉េចដែរ ពូគិតថាតុលាការហ្នឹងគេកាត់ទោសត្រឹមត្រូវដែរឬមិនត្រឹមត្រូវទេតាមចិត្តពូផ្ទាល់?

ថូន ៖ បើតាមខ្ញុំវាអត់ដឹងដែរ ព្រោះវាមិនដែលបានតាមដានឲ្យបានដិតដល់ ជួនកាលបើកចំតែមួយភ្លាតអញ្ចឹងទៅ បានមើលភ្លាតនោះព្រោះនៅតែធ្វើការអត់ដែលបានមើលដ៏អញ្ចឹងមិនដឹងថាគាត់និយាយពីសាច់រឿងអីខ្លះខ្ញុំអត់ដឹង ។

ដានី ៖ កាលដែលតុលាការនាំឌុច នាំ អៀង សារី ខៀវ សំផន នួន ជា ហើយអៀង ធិរិទ្ធ យកទៅកាត់ទោសហ្នឹងពូគិតថាត្រឹមត្រូវឬមិនត្រឹមត្រូវ?

ជូន ៖ ខ្ញុំមិនយល់មិនទេ តែបើខ្ញុំនិយាយមិនដឹងថាខុសឬត្រូវទេ បើនិយាយទៅតាមគំនិតរបស់ខ្ញុំទេ ព្រោះការដឹកនាំក្នុងសង្គមមួយៗអ្នកដឹងនាំចេះតែធ្វើទៅតាមដំណើររកខុសត្រូវនោះខ្ញុំមិនដឹង តែបើតាមខ្ញុំយល់វាត្រូវហើយព្រោះវា៣ឆ្នាំ៨ខែ២០ថ្ងៃ ប្រជាជនឃើញថាអស់ច្រើនណាស់ អញ្ចឹងបានរហូតមកដល់ខ្ញុំនេះវាខ្លាចក្នុងរបបហ្នឹង អញ្ចឹងបានរត់មកដល់នេះ បើកុំតែខ្លាចខ្ញុំទៅផ្ទះបាត់ហើយ អត់បានមកដល់នេះទេ ។

ដានី ៖ កាលជំនាន់៣ឆ្នាំពូដឹងថាគេសម្លាប់មនុស្សច្រើនដែរ?

ជូន ៖ ដឹង ។

ដានី ៖ ដឹងយ៉ាំងម៉េចបានពូដឹង?

ជូន ៖ ដឹងចេះ ដូចថាក្រុមរបស់ខ្ញុំមានគ្នា១៣នាក់ ប្រធានក្រុម មុនដំបូងកងធំ ឲ្យតែឃើញឡានខ្លប់ចូលមកយប់ដឹងតែចាប់មនុស្សហើយ ចាប់តាំងពីកងធំ ក្រោយមកទៀតកង តូច ក្រោយមកទៀតក្រុមចាប់ទៅបាត់ ចាប់ទៅបាត់ៗមិនដឹងយកទៅណា ដល់អញ្ចឹងម្នាក់ៗរត់ម៉ារូបខ្លួនខំធ្វើម៉េចឲ្យតែរួចខ្លួនឯង រៀងគេៗទៅ ។

ដានី ៖ ចុះកាលហ្នឹងចាប់យកទៅបាត់ៗហ្នឹង យើងគិតថាគេយកទៅសម្លាប់ឬគេយកទៅណាយើងមានដឹងដែរឬអត់?

ជូន ៖ បើគិតក្នុងខ្លួនម្នាក់ៗនៅខាងក្រោយដឹងថាយកទៅសម្លាប់ ព្រោះចាប់ចោះ ចាប់ចងហើយចោះ បើសិនជាយកទៅធ្វើអីផ្សេងមិនធ្វើអញ្ចឹងទេ ។

ដានី ៖ ដឹងអញ្ចឹងយើងខ្លាច?

ជូន ៖ បាទ!អញ្ចឹងបានយើងរត់មកទល់ឥឡូវនេះ បើដឹងថារត់ចេញទៅវិញផុតនោះមិនបានម៉ោយ៉ាប់ទេ ។

ដានី ៖ បាទ!ពូខ្ញុំដូចជាអស់អីចង់សួរហើយ ហើយពូមានអីចង់បន្ថែមទៀតឬអត់?

ជូន ៖ ដូចអត់មានអីចង់បន្ថែមទេ ព្រោះឃើញថាការរស់នៅសព្វថ្ងៃនេះវារលូនទៅ មុខ ហើយ?

ដានី ៖ អញ្ចឹងខ្ញុំអរគុណពូច្រើន ដែលខ្ញុំដឹងពីជីវិតរបស់ពូតាំងពីដើមរហូតមកដល់សព្វថ្ងៃនេះ ។

ជូន ៖ បាទ!

«ចប់»